# បទអន្តរាគមន៍
## ឯកឧត្តម ញៀម សំអឿន អភិបាលនៃគណៈអភិបាលខេត្តរតនគិរី ថ្លែងក្នុងសន្និសីទសារព័ត៌មាន
## ស្តីពី
## “ភាពជោគជ័យក្នុងរយៈពេល៥ឆ្នាំកន្លងមក របស់រដ្ឋបាលខេត្តរតនគិរី”

ទីស្តីការគណៈរដ្ឋមន្ត្រី ថ្ងៃទី៤ ខែមេសា ឆ្នាំ២០២៣

**ជាបឋម ខ្ញុំព្រះករុណា ខ្ញុំ**

- សូមគោរពឯកឧត្តម **ផៃ ស៊ីផាន** រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី និងជាប្រធានអង្គភាពអ្នកនាំពាក្យរាជរដ្ឋាភិបាល ជាទីគោរពដ៏ខ្ពង់ខ្ពស់
- ឯកឧត្តម លោកជំទាវ លោក លោកស្រី បងប្អូនអ្នកសារព័ត៌មានមកពីគ្រប់ស្ថាប័ន ដែលមានវត្តមាននៅទីនេះ ជាទីមេត្រី!
- បងប្អូនប្រជាពលរដ្ឋដែលកំពុងទស្សនាការផ្សាយផ្ទាល់នៅគ្រប់ស្ថានីយ៍ទូរទស្សន៍ និងបណ្តាញសារព័ត៌មានទាំងអស់ ជាទីគោរពស្រលាញ់ដ៏ជ្រាលជ្រៅបំផុត។

ថ្ងៃនេះខ្ញុំពិតជាមានសេចក្តីសោមនស្សរីករាយក្រៃលែង ដែលបានចូលរួមក្នុងអង្គសន្និសីទសារព័ត៌មានស្តីពី “**ភាពជោគជ័យក្នុងរយៈពេល៥ឆ្នាំកន្លងមក របស់រដ្ឋបាលខេត្តរតនគិរី**” ដែលបានរៀបចំឡើងដោយអង្គភាពអ្នកនាំពាក្យរាជរដ្ឋាភិបាលកម្ពុជា នាឱកាសនេះ។ ខ្ញុំសូមសម្តែងនូវការដឹងអរគុណយ៉ាងជ្រាលជ្រៅជាទីបំផុតចំពោះ សម្តេច ឯកឧត្តម លោកជំទាវ លោក លោកស្រី ជាពិសេសឯកឧត្តមរដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី និងជាប្រធានអង្គភាពអ្នកនាំពាក្យរាជរដ្ឋាភិបាលកម្ពុជា ដែលបានអនុញ្ញាតឲ្យរដ្ឋបាលខេត្តរតនគិរីបានធ្វើសន្និសីទសារព័ត៌មាន ដើម្បីបង្ហាញនូវសមិទ្ធផលការងារដែលសម្រេចបានក្នុងឆ្នាំរយៈពេល៥ឆ្នាំកន្លងមកនេះ ក្រោមការដឹកនាំដ៏ត្រឹមត្រូវរបស់រាជរដ្ឋាភិបាលកម្ពុជាដែលបានដាក់ចេញនូវគោលនយោបាយជាយុទ្ធសាស្ត្រប្រកបដោយភាពឈ្លាសវៃ។

***សម្តេច ឯកឧត្តម លោកជំទាវ លោក លោកស្រី ជាទីគោរពដ៏ខ្ពង់ខ្ពស់!***

***បងប្អូនអ្នកសារព័ត៌មាន និងបងប្អូនប្រជាពលរដ្ឋ ជាទីស្នេហា!***

អនុវត្តតាមគោលនយោបាយដូចបានរៀបរាប់ខាងលើ ក្នុងរយៈពេល៥ឆ្នាំកន្លងមក រដ្ឋបាលខេត្តរតនគិរីបានចូលរួមចំណែកយ៉ាងសំខាន់ក្នុងការសម្រេចបាននូវសមិទ្ធផលសេដ្ឋកិច្ច និងសង្គមដោយខិតខំលើកកម្ពស់ការទទួលខុសត្រូវលើការងាររក្សាសន្តិសុខ សណ្តាប់ធ្នាប់ និងសុវត្ថិភាពសាធារណៈព្រមទាំងការងារអភិវឌ្ឍនៅមូលដ្ឋាន ក្នុងនោះមន្ត្រីរាជការគ្រប់លំដាប់ថ្នាក់ កងកម្លាំងគ្រប់ប្រភេទ បានផ្សារភ្ជាប់ជាមួយប្រជាពលរដ្ឋគ្រប់មជ្ឈដ្ឋាន សំដៅចូលរួមដោះស្រាយបញ្ហាប្រឈម សំណើ សំណូមពរ និងគាំទ្រជំរុញការអនុវត្តគោលនយោបាយយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤របស់រាជរដ្ឋាភិបាលឲ្យកាន់តែមានប្រសិទ្ធភាពបន្ថែមទៀត។ ក្នុងន័យនេះ តាងនាមក្រុមប្រឹក្សាខេត្ត គណៈអភិបាលខេត្ត កងកម្លាំងប្រដាប់អាវុធគ្រប់ប្រភេទ មន្ត្រីរាជការគ្រប់លំដាប់ថ្នាក់ ព្រមទាំងប្រជាពលរដ្ឋគ្រប់ជនជាតិនៅ

ក្នុងខេត្តរតនគិរី ខ្ញុំសូមលំឱនកាយសម្តែងនូវក្តីកតញ្ញូតាធម៌ដ៏ជ្រាលជ្រៅបំផុតចំពោះគំរូវីរៈភាពដឹកនាំរបស់**សម្តេចប្រធានព្រឹទ្ធសភា សម្តេចប្រធានរដ្ឋសភា និងសម្តេចតេជោ នាយករដ្ឋមន្ត្រី** ព្រមទាំងថ្នាក់ដឹកនាំនៃរាជរដ្ឋាភិបាលកម្ពុជាដែលបានដាក់ចេញនូវគោលនយោបាយដ៏ត្រឹមត្រូវប្រកបដោយគតិបណ្ឌិត ដែលធ្វើឲ្យស្ថានភាពសេដ្ឋកិច្ច និងសង្គមកាន់តែប្រសើរឡើង និងបង្កើតបាននូវវប្បធម៌បង្រួបបង្រួបជាតិ នយោបាយ និងសេដ្ឋកិច្ចបើកចំហរជើងមេឃដែលបានចាក់ឫសយ៉ាងជ្រៅ បង្កើតជាឱកាសទាក់ទាញនូវការវិនិយោគ ព្រមទាំងរក្សាបាននូវស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច ដែលជាកត្តាសំខាន់បំផុតសម្រាប់ការអភិវឌ្ឍប្រកបដោយនិរន្តរភាព សំដៅលើកកម្ពស់សិទ្ធិសេរីភាព ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ និងកាត់បន្ថយបាននូវភាពក្រីក្រជាបន្តបន្ទាប់។ ផ្អែកតាមកត្តាសុខសន្តិភាព ស្ថិរភាពនយោបាយ និងសេដ្ឋកិច្ច ដែលរាជរដ្ឋាភិបាលកម្ពុជាបានខិតខំស្តារនិងកសាងមកដោយលំបាកនេះ បានក្លាយជាមូលដ្ឋានគ្រឹះដ៏រឹងមាំ និងកំពុងផ្តល់ផ្លែផ្កាដល់ដំណើរការអភិវឌ្ឍសម្រាប់ខេត្តរតនគិរី ដោយបានប្រែក្លាយខេត្តដាច់ស្រយ៉ាលមួយនេះ ទៅជាខេត្តដែលកំពុងមានការអភិវឌ្ឍលើគ្រប់វិស័យ តាមរយៈការធ្វើពិពិធកម្មលើគ្រប់វិស័យ ការកសាងហេដ្ឋារចនាសម្ព័ន្ធផ្លូវគមនាគមន៍ ដែលជាឆ្អឹងខ្នងដ៏សំខាន់តភ្ជាប់ក្នុងតំបន់បម្រើឲ្យការដឹកជញ្ជូន ការធ្វើពាណិជ្ជកម្ម ទេសចរណ៍ និងការងារទំនាក់ទំនងគ្រប់ប្រភេទមានលក្ខណៈកាន់តែងាយស្រួល ព្រមទាំងធ្វើឲ្យសកម្មភាពសេដ្ឋកិច្ចនៅជនបទកាន់តែមានភាពរស់រវើក។ មិនត្រឹមតែប៉ុណ្ណោះ បានបង្កើតឱកាស និងផលិតភាពការងារដល់ប្រជាពលរដ្ឋនៅគ្រប់មូលដ្ឋាន និងជួយលើកកម្ពស់ជីវភាពរស់នៅរបស់បងប្អូនប្រជាពលរដ្ឋគ្រប់ជនជាតិនៅខេត្តរតនគិរី ឲ្យទទួលបានពីសកម្មភាពអភិវឌ្ឍន៍សេដ្ឋកិច្ច និងសង្គមនិងរស់នៅយ៉ាងសុខដុមរម្យនា។

**សូមអរគុណសន្តិភាព!** យើងនឹងបន្តរួមគ្នាថែរក្សានូវសន្តិភាពនេះ មិនឲ្យជនណាម្នាក់បំផ្លិចបំផ្លាញបានឡើយ។

ដើម្បីឲ្យបងប្អូនសាធារណជន និងអ្នកសារព័ត៌មានជ្រាបកាន់តែច្បាស់ពីវឌ្ឍនភាពការងារដែលរដ្ឋបាលខេត្តរតនគិរីសម្រេចបានក្នុងរយៈពេល ៥ឆ្នាំ ខ្ញុំសូមអនុញ្ញាតជម្រាបជូនដូចតទៅនេះ៖

អនុវត្តតាមផែនការអភិវឌ្ឍន៍រយៈពេល ៥ឆ្នាំរបស់រដ្ឋបាលខេត្ត បានកំណត់នូវចក្ខុវិស័យគឺ៖ **មានការអភិវឌ្ឍសេដ្ឋកិច្ច សង្គមកិច្ច សមភាពយេនឌ័រ បរិយាប័ន្នល្អ ធានាបានចីរភាពធនធានធម្មជាតិ អភិវឌ្ឍន៍ និងអភិរក្សប្រពៃណីជនជាតិដើមភាគតិចដែលល្អៗ វប្បធម៌ថ្លៃថ្នូរ សន្តិសុខ សណ្តាប់ធ្នាប់សាធារណៈល្អ ប្រជាពលរដ្ឋមានសុខភាព សុខុមាលភាព និងជីវភាពរស់នៅបានល្អប្រសើរ។** ចក្ខុវិស័យដែលបានកំណត់នេះ បានក្លាយជាផែនទីបង្ហាញអំពីគោលបំណង គោលដៅ យុទ្ធសាស្ត្រ និងដំណោះស្រាយជាអាទិភាពនានា ដែលជាតម្រូវការជាក់ស្តែងនៅមូលដ្ឋាន សម្រាប់ធ្វើសេចក្តីសម្រេចចិត្តក្នុងការប្រើប្រាស់ធនធាន និងសក្តានុពលនានា ដើម្បីឆ្លើយតបទៅនឹងតម្រូវការជាអាទិភាពរបស់ប្រជាពលរដ្ឋ ឱ្យស្របតាមគោលនយោបាយយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ របស់រាជរដ្ឋាភិបាលកម្ពុជា និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ។ ផ្អែកតាមផែនការអភិវឌ្ឍន៍រយៈពេល៥ឆ្នាំ(២០២០-២០២៤) និងកម្មវិធីវិនិយោគបីឆ្នាំរំកិលតាមបណ្តាឆ្នាំនីមួយៗរបស់រដ្ឋបាលខេត្ត ដែលបានអនុម័តដោយក្រុមប្រឹក្សាខេត្ត គឺយើងបានអនុវត្តដោយសម្រេចបានលទ្ធផលសំខាន់ៗដូចខាងក្រោម៖

## ១. ស្ថានភាពទូទៅនៃភូមិសាស្ត្រខេត្តរតនគិរី

ខេត្តរតនគិរី ស្ថិតនៅភាគឦសាន្ត នៃព្រះរាជាណាចក្រកម្ពុជា មានចម្ងាយពីរាជធានីភ្នំពេញ ៥៨៨ គីឡូម៉ែត្រ មានព្រំប្រទល់ខាងលិចជាប់នឹងខេត្តស្ទឹងត្រែង ខាងកើតជាប់នឹងខេត្តយ៉ាឡាយ និងខេត្តកន្ទូម នៃសាធារណរដ្ឋសង្គមនិយមវៀតណាម ប្រវែង ២១០គ.ម ខាងជើងជាប់នឹងខេត្តអត្តពឺ នៃសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ ប្រវែង ១៦៥គ.ម និងខាងត្បូងជាប់នឹងខេត្តមណ្ឌលគិរី។ ភូមិសាស្ត្រខេត្តជាតំបន់ខ្ពង់រាបសម្បូរភ្នំ ជ្រោះជ្រលងជងអូរ និងព្រៃឈើគ្រប់ប្រភេទ ហើយមានទន្លេឆ្លងកាត់ចំនួន ០២ គឺទន្លេសេសាន និងទន្លេស្រែពក។ ខេត្តមានផ្ទៃដីសរុប **១០.៧៨២**គីឡូម៉ែត្រក្រឡា រដ្ឋបាលដែនដីត្រូវបានចែកជា ០១ក្រុង ៨ស្រុក **៤៦**ឃុំ ៤សង្កាត់ និង**២៤៣**ភូមិ។

## ២. ស្ថានភាពប្រជាសាស្ត្រ

ផ្អែកតាមទិន្នន័យមូលដ្ឋានក្នុងឆ្នាំ២០២២ ប្រជាជនសរុបចំនួន **២២៧.២២៧**នាក់ ស្ត្រីសរុប **១០៩.៧៤៩**នាក់ អត្រាកំណើនប្រជាជនប្រចាំឆ្នាំ **២,០៣%** គ្រួសារសរុបចំនួន **៥៣.៥៨៨**គ្រួសារ និងស្ត្រីជាមេគ្រួសារមាន ៨,៣៥% ទំហំគ្រួសារជាមធ្យម ៤នាក់/ គ្រួសារ និងដង់ស៊ីតេប្រជាពលរដ្ឋ **២០**នាក់/គម$^{២}$។ ចំណែកជនជាតិដើមភាគតិចមាន ៨អម្បូរ ស្មើ ៥៦,៨៦% នៃប្រជាពលរដ្ឋសរុប។

**តារាងទី១៖ ការគ្រប់គ្រងប្រជាពលរដ្ឋ**

| ល.រ | ការបរិយាយ | ឯកតា | ២០១៨ | ២០១៩ | ២០២០ | ២០២១ | ២០២២ |
|---|---|---|---|---|---|---|---|
| ១ | ចំនួនគ្រួសារ | គ្រួសារ | ៤៦.០៨៣ | ៤៧.៧៤៨ | ៤៩.៥៥៥ | ៥១.៣៥៦ | ៥៣.៥៨៨ |
| ២ | ចំនួនប្រជាពលរដ្ឋសរុប | នាក់ | ២០១.៥៤៧ | ២០៦.៨៥៨ | ២០៨.៦៨៦ | ២១៨.៤៣៣ | ២២៧.២២៧ |
| ៣ | ប្រជាពលរដ្ឋជាស្ត្រី | នាក់ | ៩៩,២៣៨ | ១០២,៤៧៩ | ១០២.៨៩៦ | ១០៧.៣៧៣ | ១០៩.៧៤៩ |
| ៤ | ប្រជាពលរដ្ឋអាយុ១៨ឆ្នាំឡើង | នាក់ | ១០៥.២១៤ | ១១៤.២៥៤ | ១១៥.៩១១ | ១២២.៨៧១ | ១២៦.៧៧៨ |
| ៥ | **កំណើនជាមធ្យម** | **%** | **៣,៤៨** | **២,៦៣** | **០,៨៨** | **០,៤៨** | **០,២២** |

**សំគាល់៖អត្រាភាពក្រីក្រមាន ១៩,៦៧%**

អត្រាគ្រួសារមានមុខរបរធ្វើកសិកម្មជាចម្បងចំនួន៨២,៤% គ្រួសារមានមុខរបរធ្វើសិប្បកម្មជាចម្បង ចំនួន០,៧%។ គ្រួសារមានមុខរបរសេវាកម្មជាចម្បងចំនួន១៦,៩%។

ផលិតផលក្នុងស្រុក(GDP) សរុបសម្រាប់មនុស្សម្នាក់ឆ្នាំ២០១៨ ចំនួន **១.២៣៨ដុល្លា/នាក់** ដល់ឆ្នាំ២០១៩ ចំនួន **១.៣៦៤ដុល្លា/នាក់** មានកំណើនប្រចាំឆ្នាំ៨%។

**សមិទ្ធិផលសំខាន់ៗដែលអនុវត្តបាន**

គម្រោងវិនិយោគស្នើឡើងដោយរដ្ឋបាលខេត្តរយៈពេល៥ឆ្នាំសរុបចំនួ**១.២៨៣គម្រោង** តម្រូវថវិកាចំនួន ៨៤៧ពាន់ ៩១៨លាន ៤២០ពាន់រៀល ស្ថាប័ន អង្គភាពគាំទ្រគម្រោងក្នុងវេទិកាពិគ្រោះយោបល់ចំនួន **៦៦៣ គម្រោង** អនុវត្តសម្រេចបានចំនួន **៣៧០គម្រោង** ស្មើថវិកាចំនួន ១៧៦ពាន់ ៨៥០លាន១៧០ពាន់រៀលគត់ ស្មើ៧៣,៩០%។

គម្រោងស្នើឡើងដោយរដ្ឋបាលឃុំ សង្កាត់រយៈពេល៥ឆ្នាំសរុបចំនួន ១២.៧១១គម្រោង តម្រូវថវិកាចំនួន៤១៥ពាន់០៨៧លាន១៨០ពាន់រៀល ស្ថាប័ន អង្គភាពគាំទ្រគម្រោងក្នុងសិក្ខាសាលាសមាហរណកម្មមានចំនួន ៤.៨២៣ គម្រោង អនុវត្តសម្រេចបានចំនួន **៣.២៤៧គម្រោង** ស្មើថវិកាចំនួន ៧៦ពាន់១៨៣លាន៥២០ពាន់រៀលគត់ ស្មើ៧៣,៩០%។

**ការអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូន**

| លរ | ការបរិយាយ | ឯកតា | ២០១៨ | ២០១៩ | ២០២០ | ២០២១ | ២០២២ | សរុប |
|---|---|---|---|---|---|---|---|---|
| ១ | ផ្លូវកៅស៊ូ | គ.ម | ៥,៨ | ១២,៥ | ៤,០៣ | ១,៦៥ | ០,៣៨ | ២៤,៣៦ |
| ២ | ផ្លូវបេតុង | គ.ម | ២,៩៩ | ៥,២៥៦ | ៨,៩៦៧ | ៤,៨១៨ | ១០,៤៧ | ៣២,៤៩៨ |
| ៣ | ផ្លូវក្រាលគ្រួស | គ.ម | ១៨៩,៥៣ | ២១៤,៣៣៥ | ២៨៣,៨៥៤ | ២១២,២៧៨ | ២២៣,៦៤ | ១.១២៣ |
| ៤ | សាងសង់លូមូល បណ្ដោយផ្លូវ | ម៉ែត្រ | ៨១៥ | ១.៥៧២ | ១.៥៣២ | ៨៧២ | ៣.៨២៧ | ៨.៦១៨ |

គម្រោងទាំងអស់អនុវត្តឡើងសំដៅធ្វើឱ្យប្រសើរឡើងនូវការដឹកជញ្ជូន ការចរាចរណ៍ និងការផ្ដល់សេវាជូនប្រជាពលរដ្ឋនៅក្នុងមូលដ្ឋានក៏ដូចជាក្នុងតំបន់។

**២. ការលើកស្ទួយវិស័យអភិវឌ្ឍន៍ជនបទ**

ទស្សនវិស័យរបស់រាជរដ្ឋាភិបាលកម្ពុជា បានកំណត់ថា **"ឆ្នាំ២០២៥ ប្រជាពលរដ្ឋនៅសហគមន៍ជនបទគ្រប់រូបត្រូវមានការផ្គត់ផ្គង់ទឹកស្អាត និងអនាម័យគ្រប់គ្រាន់ និងរស់នៅក្នុងបរិស្ថានដែលមានអនាម័យប្រកបដោយនិរន្តរភាព"** ស្ថានភាពការអភិវឌ្ឍនៅតាមជនបទក្នុងខេត្ត រួមមាន៖

- បានថែទាំផ្លូវជាលក្ខណៈខួប និងប្រចាំ ចំនួន **៣១ខ្សែ** ប្រវែង **៤៣៩.៧៥ គ.ម**។

- អត្រាគ្របដណ្តប់ទឹកស្អាតទូទាំងខេត្ត មានចំនួន **៧១,៧៦%** កើនឡើង **១៤,១៦%** ធៀបនឹងឆ្នាំ២០១៨ មានត្រឹម **៥៧,៦០%** អត្រាកំណើនក្នុងមួយឆ្នាំ **២,៨៣%**។
- អត្រាអនាម័យជនបទគ្របដណ្តប់ទូទាំងខេត្ត **៦០%** កើនឡើង **២១%** បើធៀបនឹងឆ្នាំ ២០១៨ មានត្រឹម **៣៩%** អត្រាកំណើនក្នុងមួយឆ្នាំ ៤,២%។
- ផ្ទះដែលមានបង្គន់អនាម័យប្រើប្រាស់សរុបចំនួន **២៣,៧៧៤ខ្នងផ្ទះ** ខ្នងផ្ទះសរុបចំនួន **៤៥.៨៤០ខ្នង ស្មើនឹង ៥១,៨៦%**។
- ភូមិដែលបានបញ្ឈប់ការបន្ទោរបង់ពាសវាលពាសកាល (ODF) ចំនួន ៥៥ ភូមិ ស្មើនឹង ៧ ឃុំ និង ១ស្រុក។

## ៣. ការខារថាមពលអគ្គិសនី

ក្នុងឆ្នាំ២០១៨ មានប្រភពផ្គត់ផ្គង់ចំនួន ៣ (ផលិតក្នុងខេត្ត ទិញពីប្រទេសវៀតណាម និងទិញពីស្ទឹងត្រែង) បន្ទុកប្រើប្រាស់ចំនួន **១៨,០២MW** ភូមិមានអគ្គីសនីប្រើប្រាស់ចំនួន **១២៦/២៤៣ភូមិ** ស្មើនឹង **៥១,៩%** ហើយគ្រួសារមានអគ្គិសនីប្រើប្រាស់ចំនួន **១២.៧៤៣គ្រួសារ** ស្មើនឹង **២៩,៦%**។

គិតត្រឹមឆ្នាំ២០២២ មានប្រភពផ្គត់ផ្គង់ចំនួន ៤ (ផលិតក្នុងខេត្ត ទិញពីប្រទេសវៀតណាម ទិញពីស្ទឹងត្រែង និងទិញពីអនុស្ថានីយ៍) បន្ទុកប្រើប្រាស់ចំនួន **២១,១៨MW** ភូមិមានអគ្គីសនីប្រើប្រាស់ចំនួន **២៣១/២៤៣ភូមិ** ស្មើនឹង **៩៥,៦%** គ្រួសារមានអគ្គិសនីប្រើប្រាស់ ចំនួន **២៤.០១៣គ្រួសារ** ស្មើនឹង **៥១,៧%**។

## ៤. វិស័យកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

វិស័យកសិកម្មត្រូវបានចាត់ទុកជាវិស័យអាទិភាពក្នុងការលើកកម្ពស់សេដ្ឋកិច្ចរបស់ប្រជាពលរដ្ឋ ដោយអត្រាមុខរបរពឹងផ្អែកលើវិស័យកសិកម្មនៅក្នុងខេត្ត មានចំនួន **៨១,១០%** នៃប្រជាជនសរុប ហើយអត្រានេះមានការប្រែប្រួលតិចបំផុត។

**តារាងទី១៖ ផ្ទៃដីកសិកម្ម និងវឌ្ឍភាពការងារកសិកម្ម**

| ការបរិយាយ | ឯកតា | ២០១៨ | ២០១៩ | ២០២០ | ២០២១ | ២០២២ |
|---|---|---|---|---|---|---|
| ផ្ទៃដីដំណាំស្រូវ | ហិកតា | ២៧.០៣៣ | ២៦.២៧២ | ២៦.២៧២ | ៣០.៨៤៤ | ៣០.៨៤៤ |
| បរិមាណផលស្រូវ | តោន | ៦០.៦០៧ | ៦០.៧០២ | ៧៦.៨៣៦ | ៧៤.៤០៤ | ៧៦.៣៤២ |
| តុល្យភាពស្បៀងគិតជាអង្ករ | តោន | ១.៤២៦ | ១៩០ | ៧.៨៣២ | ៧.៥១៦ | ៧.១០០ |
| ដំណាំចន្ទី | ហិកតា | ៣៤.៧៣៨ | ៣៩.៧៨៤ | ៤៥.០៦៨ | ៥១.៦៤២ | ៦១.៥៤៨ |
| ផ្ទៃដីប្រមូលផល | ហិកតា | ២០.៩៨៦ | ២០.៩៨៦ | ៣១.០៧២ | ៤១.៨០២ | ៥១.៦៤២ |
| បរិមាណផល | តោន | ១៣.៣៤៣ | ១១.៣០៦ | ១៥.០៥៥ | ៦២.០៩២ | ៧៦.៥៦៤ |
| ដំណាំកៅស៊ូ | ហិកតា | ៦៧.៤១៧ | ៦៧.៣៧៣ | ៦៥.០៧១ | ៦៦.៩៣២ | ៦៦.៦៧០ |
| ដំឡូងមី | ហិកតា | ១៧.៧១០ | ១៧.៥៦៨ | ១៤.៥៥៣ | ១៥.៩៨២ | ១៥.៦៣២ |
| បរិមាណផល | តោន | ២៦៧.១៩៥ | ២៤៥.៩៩៣ | ២០៨.៤៤៣ | ៣៣៦.១៥៣ | ៤៣៨.៤៩៤ |

| | | | | | | |
|---|---|---|---|---|---|---|
| ផ្ទៃដីកៅស៊ូ | ហិកតា | ៦៧.៤១៧ | ៦៧.៣៧៤ | ៦៥.០៧១ | ៦៦.៣៣ | ៦៦.៦៧០ |
| ផ្ទៃដីអាជីវកម្ម | ហិកតា | ៣០.៥៥១ | ៤១.១៨៨ | ៤១.៧៩៤ | ៤៨.៣៦៥ | ៥៤.០៤៦ |
| បរិមាណផលកៅស៊ូក្រែប | តោន | ២២.៦១៨ | ២៥.៦៨៤ | ៤៥.៩៧៣ | ៤៨.៣៦៥ | ៥១.១២៤ |
| រោងចក្រកែច្នៃកៅស៊ូ | កន្លែង | ០៧ | ០៧ | ០៧ | ០៧ | ០៧ |
| គ្រឿងយន្តកសិកម្ម | គ្រឿង | ៤.៩៥៦ | ៥.៥០៨ | ៦.៣៩៦ | ៦.២៨១ | ៦.៥៧៨ |

### តារាងទី២៖ ស្ថិតិសត្វ និងវឌ្ឍភាព

| ល | ការបរិយាយ | ២០១៨ | ២០១៩ | ២០២០ | ២០២១ | ២០២២ |
|---|---|---|---|---|---|---|
| | គោ ក្របី | ៤៧.០៤៦ | ៤៧.៧៩៦ | ៤៨.៥១០ | ៤៨.៩៦៨ | ៥០.៣៨២ |
| | ជ្រូក | ៣៥.៥៨៤ | ១៧.៨២១ | ១៥.៦៩៩ | ១៧.០២៩ | ១៨.៤២២ |
| | បក្សីមាន់ ទា | ២៣០.៧៣២ | ២៥៣.៦៥០ | ១៩១.១៧៤ | ២០០.៥៨១ | ២២៤.៣៣៩ |

ឯកតា៖ គិតជាក្បាល

តាមតារាងខាងលើការចិញ្ចឹមជ្រូកមានការថយចុះចាប់ពីឆ្នាំ២០១៩ដោយសារមានករណីផ្ទុះជម្ងឺប៉េស្តជ្រូកអាហ្វ្រិកនៅស្រុកអូរយ៉ាដាវ។

### តារាងទី៣៖ ស្ថិតិផលនេសាទ និងនាំចូល

| ការបរិយាយ | ២០១៨ | ២០១៩ | ២០២០ | ២០២១ | ២០២២ |
|---|---|---|---|---|---|
| នេសាទតាមដងទន្លេនិងបឹងអូរ | ៥៣៥ | ១៤៨២ | ១២១៦ | ១៣៦១ | ១២៤០ |
| ផលវារីវប្បកម្ម | ៣៥ | ៤២ | ២៣៣ | ១៥២ | ១៥៦ |
| ការនាំផលត្រី | ១២១ | ២២១ | ៦៦០ | ២៣៧ | ៣៧៥ |

ឯកតា៖ គិតជាតោន

### តារាងទី៤៖ ក្រុមហ៊ុនវិនិយោគសម្បទានដីសេដ្ឋកិច្ច និងវឌ្ឍនភាព

| ការបរិយាយ | ២០១៨ | ២០១៩ | ២០២០ | ២០២១ | ២០២២ |
|---|---|---|---|---|---|
| ចំនួនក្រុមហ៊ុន | ២៧ | ២៧ | ២៧ | ២៧ | ២៧ |
| ផ្ទៃដីវិនិយោគចុះកិច្ចសន្យា (ហិកតា) | ១៥៣.២២២ | ១២៤.៦៦៩ | ១២៤.៦៦៩ | ១០២.៨៦១ | ១១២.៩៧៤ |
| ផ្ទៃដីអាជីវកម្ម (ហិកតា) | ១៤៨.៧៥៥ | ៨៧.៧០០ | ៨៧.៧០០ | ៨៧.៧០០ | ៨៣.៧៨៥ |
| ផ្ទៃដីដាំដុះកៅស៊ូនិងដំណាំ (ហិកតា) | ៤៩.៦៥៨ | ៥៣.៤៧៥ | ៤០.៩៨២ | ៤៩.៩៨២ | ៤១.៦២៧ |
| បុគ្គលិកកម្មករ | ៣.៦១០ | ៧.២៤៩ | ៧.៧១៩ | ១៣.៩៦៥ | ១៦.៩៣៥ |

| | | | | | |
|---|---|---|---|---|---|
| កម្មករជើងកាល | ៩៦៣ | ២.០៩០ | ២.០៦៤ | ៤.៤២៣ | ៦.៣៨៩ |

**តារាងទី៥៖ ការនាំចេញកសិផល និងកៅស៊ូរបស់ក្រុមហ៊ុនវិនិយោគ (តាមច្រកព្រំដែនអូរយ៉ាដាវ)**

| បរិយាយ | ឯកតា | ២០១៨ | ២០១៩ | ២០២០ | ២០២១ | ២០២២ |
|---|---|---|---|---|---|---|
| ការនាំចេញកៅស៊ូក្រែប | តោន | ៥.៥៣៤ | ៨.៨២២ | ៨.១៧២ | ១១.១៤៧ | ១០.៦០៣ |
| កសិផលផ្សេងៗ | តោន | ៣.៥២៦ | ៦.៤១៩ | ៦២.៥៤១ | ៧៨.៧០៦ | ១២៩.០៩១ |

នៅក្នុងខេត្តមានរោងចក្រកែច្នៃម្សៅមី១កន្លែង មានសមត្ថភាពផលិត១.២០០តោន/២៤ម៉ោង (គិតជាម្សៅពី៣០០តោន) ឆ្នាំ២០២២ ក្រុមហ៊ុនបាននាំចេញម្ស៉ៅមីចំនួន ២.៦២២តោន តាមច្រកទ្វារអន្តរជាតិអូរយ៉ាដាវ។

### ៥. ការទំនាក់ទំនងពាណិជ្ជកម្ម

ទំហំពាណិជ្ជកម្មជាមួយវៀតណាម ការនាំចេញផលិតផលកសិកម្មរយៈពេល ៥ឆ្នាំ គិតចាប់ពីឆ្នាំ ២០១៨ ដល់ ឆ្នាំ២០២២។

**<u>ទំនិញនាំចេញ</u>**

| ល.រ | បរិយាយ | ឆ្នា២០១៨ តោន | ឆ្នាំ២០១៩ តោន | ឆ្នាំ២០២០ តោន | ឆ្នាំ២០២១ តោន | ឆ្នាំ២០២២ តោន |
|---|---|---|---|---|---|---|
| ១ | កៅស៊ូក្រែប | 7,560.730 | 13,348.440 | 8,397.620 | 12,552.825 | 14,873.752 |
| ២ | ផ្លែចេក | 2,850.550 | 7,707.716 | 93,959.764 | 95,230.774 | 131,802.438 |
| ៣ | ផ្លែខ្នុរ | 0.00 | 560.727 | 383.624 | 394.556 | 0.00 |
| ៤ | ផ្លែស្វាយ | 75.00 | 89.650 | 1,648.995 | 2,479.326 | 2,262.846 |
| ៥ | ផ្លែស្រកានាគ | 617.507 | 977.411 | 380.856 | 0.00 | 0.00 |
| ៦ | ផ្លែម្នាស់ | 0.00 | 0.00 | 0.00 | 2,569.432 | 1,198.236 |
| ៧ | ផ្លែមៀន | 0.00 | 0.00 | 246.379 | 68.069 | 212.458 |
| ៨ | ផ្លែក្រូចថ្លុង | 0.00 | 0.00 | 0.00 | 33.265 | 0.00 |
| ៩ | គ្រប់ស្វាយចន្ទី | 450.500 | 541.148 | 80.000 | 0.00 | 6,546.000 |
| ១០ | ម្សៅដំឡូងមី | 0.00 | 0.00 | 15.056 | 0.00 | 2,872.000 |
| ១១ | ថ្មម៉ាប | 0.00 | 0.00 | 0.00 | 222.640 | 822.000 |
| សរុប | | 11,554.287 | 23,225.092 | 105,112.294 | 113,550.887 | 160,589.730 |
| សរុបទំនិញនាំចេញទាំង ៥ ឆ្នាំ | | | | | | 414,032.290 |

**ទំនិញនាំចូល** ៖

| ល.រ | បរិយាយ | ឆ្នាំ២០១៨ តោន | ឆ្នាំ២០១៩ តោន | ឆ្នាំ២០២០ តោន | ឆ្នាំ២០២១ តោន | ឆ្នាំ២០២២ តោន |
|---|---|---|---|---|---|---|
| ១ | ក្រដាសកាតុង | 5,250.00 | 7,497.687 | 16,725.311 | 16,009.729 | 12,470.334 |
| ២ | ថង់ការពារផ្លែឈើ | 825.285 | 1,280.478 | 2,170.339 | 398.904 | 25,694.400 |
| ៣ | ទុយោជ័រ | 1,350.350 | 1,445.922 | 576.309 | 1,105.569 | 2,290.551 |
| ៤ | ស្នោទ្រាប់ផ្លែឈើ | 0.00 | 0.00 | 659.316 | 205.395 | 0.00 |
| ៥ | ជីកសិកម្ម | 2,171.230 | 2,528.164 | 9,482.270 | 32,237.732 | 42,880.523 |
| ៦ | ថ្នាំកសិកម្ម | 50.250 | 61.432 | 0.00 | 0.00 | 4.242 |
| ៧ | កូនម្នាស់ | 0.00 | 0.00 | 1,513.573 | 0.00 | 0.00 |
| ៨ | ផ្លែល្មៅ | 0.00 | 0.00 | 0.00 | 423.883 | 0.00 |
| ៩ | កញ្ចក់ | 0.00 | 0.00 | 0.00 | 50.000 | 0.00 |
| ១០ | ផ្សេងៗ | 1,250.470 | 1,653.891 | 7,642.885 | 4,142.759 | 9,363.853 |
| សរុប | | 10,897.585 | 14,467.574 | 38,770.003 | 54,573.971 | 92,703.903 |
| **សរុបទំនិញនាំចូលទាំង ៥ ឆ្នាំ** | | | | | **211,413.036 តោន** | |

## ៦.វិស័យអប់រំ យុវជន និងកីឡា

ឆ្លើយតបទៅនឹងគោលនយោបាយយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ ដែលបានកំណត់យកការអភិវឌ្ឍធនធានមនុស្ស ជាអាទិភាពទី១ និងអនុវត្តតាមផែនការយុទ្ធសាស្ត្រវិស័យអប់រំ២០១៩-២០២៣ សំដៅឆ្ពោះទៅឆ្នាំ២០៣០ ព្រមទាំងឆ្លើយតបទៅនឹងចក្ខុវិស័យអភិវឌ្ឍន៍សេដ្ឋកិច្ច សង្គមកិច្ចកម្ពុជា និងកម្មវិធីកំណែទម្រង់នានា ក្នុងនាមអាជ្ញាធរខេត្ត ដោយមានមន្ទីរអប់រំ យុវជន និងកីឡាខេត្តជាសេនាធិការ បានខិតខំអនុវត្តសម្រេចបាននូវលទ្ធផលរួមមាន៖

- ឆ្នាំ២០១៨ នៅទូទាំងខេត្តមានសាលាមត្តេយ្យសិក្សាសហគមន៍និងរដ្ឋ សរុបចំនួន ១៨៤ សាលា និងគ្រឹះស្ថានសិក្សាសាធារណៈរដ្ឋ សរុបចំនួន **២៨៩សាលា** មានសិស្សសរុបចំនួន **៤៧.៣១៩នាក់**។
- ឆ្នាំ២០២២ មានសាលាមត្តេយ្យសិក្សាសហគមន៍និងរដ្ឋ សរុបចំនួន **១៨៨សាលា** និងគ្រឹះស្ថានសិក្សាសាធារណៈរដ្ឋ សរុបចំនួន **២៨៩សាលា** មានសិស្សសរុបចំនួន **៥៩.៣៥៣នាក់**។
- ឆ្នាំ២០១៨ សិស្សប្រឡងសញ្ញាបតមធ្យមសិក្សាទុតិយភូមិជាប់ និទ្ទេសA **១**នាក់
- ឆ្នាំ២០២២ សិស្សប្រឡងសញ្ញាបតមធ្យមសិក្សាទុតិយភូមិជាប់ និទ្ទេសA **៩**នាក់។
- អត្រាសិស្សមធ្យមសិក្សាបឋមភូមិបានប្រឡងជាប់ចន្លោះពី ៨៦% ទៅ ៩៤%
- អត្រាសិស្សមធ្យមសិក្សាទុតិយភូមិបានប្រឡងជាប់ចន្លោះពី ៦៧% ទៅ ៩០%។

**តារាង៖ គ្រឹះស្ថានសិក្សាឯកជន (សាលា/កន្លែង)**

| ល.រ | ការបរិយាយ | ២០១៨ | ២០១៩ | ២០២០ | ២០២១ | ២០២២ |
|---|---|---|---|---|---|---|

| | | | | | | |
|---|---|---|---|---|---|---|
| ១ | មត្តេយ្យសិក្សា | ០៥ | ០៥ | ០៤ | ០៤ | ០៤ |
| ២ | បឋមសិក្សា | ០៥ | ០៥ | ០៥ | ០៤ | ០៤ |
| ៣ | មធ្យមសិក្សាបឋមភូមិ | ០៤ | ០០ | ០០ | ០០ | ០០ |
| ៤ | មធ្យមសិក្សាទុតិយភូមិ | ០០ | ០៤ | ០៤ | ០៤ | ០៤ |
| ៥ | ឧត្តមសិក្សា | ០១ | ០១ | ០២ | ០២ | ០២ |
| **សរុប** | | **១៥** | **១៥** | **១៥** | **១៤** | **១៤** |

## ៧. វិស័យសុខាភិបាល

សមិទ្ធផលជាច្រើនក្នុងវិស័យសុខាភិបាលកំពុងបន្តកើតមាន ក្នុងការផ្តល់សេវាសុខភាពតាមរយៈការអន្តរាគមន៍នៃកម្មវិធីសុខភាពបន្តពូជ សុខភាពមាតា-ទារក កុមារ និងអាហារូបត្ថម្ភលើស្ត្រី និងកុមារ កម្មវិធីប្រយុទ្ធនឹងជំងឺឆ្លង ជំងឺមិនឆ្លងរ៉ាំរ៉ៃ និងបញ្ហាសុខភាពសាធារណៈ។ រដ្ឋបាលខេត្ត ដោយមានមន្ទីរសុខាភិបាលនៃរដ្ឋបាលខេត្ត ជាសេនាធិការ និងតាមរយៈក្រសួងសុខាភិបាល បានខិតខំវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធសុខាភិបាលមានជាអាទិ៍ ការសាងសង់ថ្មី ពង្រីក និងជួសជុលប៉ុស្តិ៍សុខភាព មណ្ឌលសុខភាព និងមន្ទីរពេទ្យបង្អែក ការផ្គត់ផ្គង់ឱសថបរិក្ខានិងឧបករណ៍ពេទ្យ បណ្តាញទំនាក់ទំនង និងមធ្យោបាយដឹកជញ្ជូន ព្រមទាំងអភិវឌ្ឍន៍ធនធានមនុស្ស(សមត្ថភាព ជំនាញ)ជាដើម។

សមិទ្ធផល និងវឌ្ឍនភាពដែលវិស័យសុខាភិបាលសម្រេចបានក្នុងរយៈពេល៥ឆ្នាំនេះ គឺអាស្រ័យលើកត្តាគន្លឹះចំបងៗរួមមាន៖

១.ការដាក់ចេញនូវកម្មវិធីនយោបាយដ៏ត្រឹមត្រូវរបស់រាជរដ្ឋាភិបាលកម្ពុជា

២.ការដាក់ចេញនូវផែនការយុទ្ធសាស្ត្រច្បាស់លាស់របស់ក្រសួងសុខាភិបាល ផ្តល់ជាមូលដ្ឋានគ្រឹះសម្រាប់អនុវត្ត

៣.ចិរភាពនៃកំណើនសេដ្ឋកិច្ចជាតិបានបង្កើនលំហពន្ធ ផ្តល់លទ្ធភាពដល់រាជរដ្ឋាភិបាលបង្កើនការចំណាយថវិកាជាតិលើការថែទាំសុខភាពប្រជាជន

៤.ការខិតខំប្រឹងប្រែងជំនះរាល់ឧបសគ្គ ប្តេជ្ញាចិត្តអនុវត្តកម្មវិធីរបស់មន្ត្រី បុគ្គលិកសុខាភិបាលគ្រប់លំដាប់ថ្នាក់ ក្នុងការបំពេញភារកិច្ចរបស់ខ្លួនក្នុងតួនាទីជាមន្ត្រីសាធារណៈ បំរើសុខភាពប្រជាពលរដ្ឋ

៥.ការឧបត្ថម្ភគាំទ្រ និងកិច្ចសហការពីគ្រប់អ្នកពាក់ព័ន្ធ សប្បុរសជននានា

៦.ការផ្តល់ជំនឿចិត្តពីប្រជាពលរដ្ឋលើការផ្តល់សេវាសុខាភិបាល។

**តារាងទី១៖ វឌ្ឍនភាពហេដ្ឋារចនាសម្ព័ន្ធ និងការផ្តល់សេវាសុខភិបាល**

| ល.រ | ការបរិយាយ | ២០១៨ | ២០១៩ | ២០២០ | ២០២១ | ២០២២ |
|---|---|---|---|---|---|---|
| ១ | មន្ទីរពេទ្យបង្អែក | ០២ | ០២ | ០២ | ០២ | ០២ |
| ២ | មណ្ឌលសុខភាព | ២៧ | ២៧ | ២៧ | ៣០ | ៣០ |
| ៣ | ប៉ុស្តិ៍សុខភាព | ០៧ | ០៧ | ០៧ | ០៦ | ០៦ |

**តារាងទី២៖ សេវាសុខាភិបាលឯកជន**

| ល.រ | ការបរិយាយ | ២០១៨ | ២០១៩ | ២០២០ | ២០២១ | ២០២២ |
|---|---|---|---|---|---|---|

| | | | | | | |
|---|---|---|---|---|---|---|
| ១ | មន្ទីរពេទ្យឯកជន | ០៥ | ០៦ | ០៧ | ០៧ | ០៧ |
| ២ | ឱសថស្ថាន គ្លីនិក បន្ទប់ថែទាំផ្សេងៗ | ២២៨ | ២៤៩ | ២៨៨ | ២៩៨ | ៣០៣ |

**៨. ការងារសង្គមកិច្ច**

គ្រួសារក្រីក្រក្នុងខេត្តសរុប **១៥.៤៧៤គ្រួសារ** ក្នុងនោះក្រ១ ចំនួន **៥.៣៣៣គ្រួសារ** ក្រ២ ចំនួន **១០.១៤១គ្រួសារ** តាមរយៈការធ្វើបច្ចុប្បន្នភាពកន្លងមកបានលុបប័ណ្ណក្រីក្រចំនួន **២៨៩គ្រួសារ**។

ដើម្បីសម្រេចបាននូវចក្ខុវិស័យរយៈពេលវែង ប្រែក្លាយកម្ពុជាទៅជាប្រទេសមានប្រាក់ចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០ និងប្រទេសមានចំណូលខ្ពស់នៅឆ្នាំ២០៥០ រាជរដ្ឋាភិបាលបានដាក់ចេញនូវគោលនយោបាយ និងយុទ្ធសាស្ត្រជាច្រើន ក្នុងនោះក្របខណ្ឌគោលនយោបាយជាតិគាំពារសង្គម ២០១៦-២០២៥ ក៏ត្រូវបានរាជរដ្ឋាភិបាលដាក់ចេញក្នុងគោលបំណងលើកកម្ពស់សុខភាពមនុស្សគ្រប់រូប ជាពិសេសជនរងគ្រោះ និងងាយរងគ្រោះក្នុងសង្គម។

-អនុវត្តតាមគោលនយោបាយនេះ នៅក្នុងខេត្តរតនគិរី គិតចាប់ពីខែមិថុនា ឆ្នាំ២០១៩ ដល់ខែកញ្ញា ឆ្នាំ២០២២ ការងារផ្តល់ប័ណ្ណក្រីក្រ ប័ណ្ណសមធម៌ ការងារផ្តល់សាច់ប្រាក់ស្ត្រីមានផ្ទៃពោះ សរុបចំនួន **៥.៥៦៣នាក់** ចំណាយថវិកាសរុបប្រមាណជាង **១៣ន់លានរៀល** និងកុមារអាយុ២ឆ្នាំ ១.៥១៥ ចំណាយថវិកាប្រមាណជាង **៥០០លានរៀល**។

-ដោយឡែកអំឡុងពេលវិបត្តិកូវីដ-១៩ និងសម្ពាធអតិផរណា រាជរដ្ឋាភិបាលបានដាក់ចេញនូវកម្មវិធី ឧបត្ថម្ភសាច់ប្រាក់ជូនគ្រួសារក្រីក្រ និងងាយរងគ្រោះក្នុងអំឡុងពេលប្រយុទ្ធនឹងជំងឺកូវីដ-១៩ គិតចាប់ពីថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០២១ មកទល់ឆ្នាំ២០២២ សម្រេចបានចំនួន **១៥.៥០២គ្រួសារ** ចំណាយថវិកាប្រមាណជាង **៧៧.៧៦៥លានរៀល** និងឧបត្ថម្ភគ្រួសារក្រីក្រងាយរងហានិភ័យអំឡុងពេលសម្ពាធអតិផរណា ចំនួន **៧.២៩២គ្រួសារ** ចំណាយថវិកាប្រមាណជាង **១.០៤៣លានរៀល**។

-គ្រួសារងាយរងគ្រោះ និងរងគ្រោះតាមសហគមន៍ ទទួលបានជំនួយសង្គ្រោះបន្ទាន់សរុប **៣.៦៦៦**គ្រួសារ។

-ជនរងគ្រោះដោយអំពើជួញដូរមនុស្សតាមទំរងនិងរំលោភបំពានផ្លូវភេទទទួលបានសេវាថែទាំសរុប មានចំនួន **៦៧នាក់**។

***៩. សហគ្រាសធុនតូច និងមធ្យម***

សហគ្រាសធុនតូច និងមធ្យម(SME) ត្រូវបានចាត់ទុកថាជាក្បាលម៉ាស៊ីននៃកំណើនសេដ្ឋកិច្ច ដោយបានរួមចំណែកក្នុងការអភិវឌ្ឍសេដ្ឋកិច្ច និងបង្កើតការងារក្នុងប្រទេស។

នៅឆ្នាំ២០១៨ នៅក្នុងខេត្តមាន សហគ្រាសធុនតូច និងមធ្យម ចំនួន **១៧៧មូលដ្ឋាន** មានកម្លាំងពលកម្មចំនួន **៩៣១នាក់** និងនៅឆ្នាំ២០២២នេះ មានចំនួន **២០១មូលដ្ឋាន** (កើនឡើង ២៤ មូលដ្ឋាន) មានកម្លាំងពលកម្ម ចំនួន **១.០៤៧នាក់** ។

**១០. វិស័យទេសចរណ៍**

រមណីយដ្ឋានទេសចរណ៍ក្នុងខេត្តរតនគិរី មានចំនួន ៣០កន្លែង ក្នុងនោះរួមមាន រមណីយដ្ឋានធម្មជាតិចំនួន ២០កន្លែង រមណីយដ្ឋានវប្បធម៌ធម្មជាតិចំនួន ០២កន្លែងនិងកៃច្នៃចំនួន ៨កន្លែង។

| បរិយាយ | ឯកតា | ២០១៨ | ២០១៩ | ២០២០ | ២០២១ | ២០២២ | ភ្ញៀវសរុប |
|---|---|---|---|---|---|---|---|
| ភ្ញៀវជាតិ | នាក់ | ១៥៣.៣៨១ | ២០៦.៦៨២ | ១៨៧.៣៧៦ | ១២០.៩៦៥ | ២៨៩.១៦០ | **៩៥៧.៥៦៤** |
| អន្តរជាតិ | នាក់ | ២០.៥៤៤ | ២៥.១៩១ | ៥.៩៥៣ | ៥៥០ | ៤.២៦៣ | **៥៦.៥០១** |
| សរុប | នាក់ | **១៧៣.៩២៥** | **២៣១.៨៧៣** | **១៩៣.៣២៩** | **១២១.៥១៥** | **២៩៣.៤២៣** | **១.០១៤.០៦៥** |

សរុបសេចក្តីមក អ្វីដែលខ្ញុំបានបង្ហាញជូនខាងលើ គឺវាជាសមិទ្ធផលរួមដែលរដ្ឋបាលខេត្តរតនគិរីសម្រាចបានកន្លងមក ក្រោមកិច្ចខិតខំប្រឹងប្រែង ទាំងថ្នាក់ដឹកនាំ មន្ត្រីរាជការ ព្រមទាំងវិស័យឯកជន អង្គការដៃគូរអភិវឌ្ឍន៍នានា និងប្រជាពលរដ្ឋទូទៅក្នុងខេត្ត រួមសហការគ្នា ជំនះការលំបាក និងឧបសគ្គគ្រប់បែបយ៉ាង ដោយឈរលើមូលដ្ឋាន រួមគិត រួមធ្វើ និងរួមទទួលខុសត្រូវ។

នៅក្នុងពិធីនេះ ក្រៅពីអ្វីដែលខ្ញុំបានលើកឡើង នៅមានសមិទ្ធផលជាច្រើនទៀតដែលវិស័យជំនាញពាក់ព័ន្ធមួយចំនួនអាចនឹងបញ្ជាក់ជូនបន្ថែមដល់សាធារណជន ក៏ដូចអ្នកសារព័ត៌មាននៅទីនេះ ដើម្បីជូនជ្រាបឲ្យកាន់តែច្បាស់។

ជាទីបញ្ចប់ ខ្ញុំសូមបួងសួងដល់វត្ថុស័ក្តិសិទ្ធ ទេវតារក្សាឆ្នាំថ្មី សូមប្រសិទ្ធពរថ្វាយ ប្រគេន សម្តេចព្រះអគ្គមហាសង្ឃរាជទាំងពីរគណៈ សម្តេចព្រះមហាក្សត្រី ព្រះវររាជមាតាជាតិខ្មែរ ព្រះករុណា ព្រះបាទសម្តេចព្រះបរមនាថ ព្រះមហាក្សត្រនៃព្រះរាជណាចក្រកម្ពុជា សម្តេចប្រធានព្រឹទ្ធសភា សម្តេចប្រធានរដ្ឋសភា និងសម្តេចតេជោនាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា និងសូមគោរពជូនពរសម្តេច ទ្រង់ ឯកឧត្តម លោកជំទាវ លោក លោកស្រី បងប្អូនប្រជាពលរដ្ឋ និងបងប្អូនអ្នកសារព័ត៌មានទាំងអស់ សូមទទួលបាននូវសុខសុវត្ថិភាព និងសមប្រកបតែនឹងពុទ្ធពរបួនប្រការ អាយុ វណ្ណៈ សុខៈ និងពលៈ កុំបីឃ្លៀងឃ្លាតឡើយ៕

**សូមអរព្រះគុណ និងអរគុណ!**